ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៧ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៧ សម្រាប់ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញស្តីពីបញ្ហាប្រឈមរបស់អ្នកជំងឺអេដស៍ ទៅនឹងជំងឺឱកាសនិយមផ្សេងៗ បង្ហាញជូនដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

-ការបង្ហាញពីទម្រង់របាយការណ៍សម្រាប់ក្រសួង ស្ថាប័ន រៀបចំផ្ញើមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-បទបង្ហាញស្តីពីការឆ្លងមេរោគអេដស៍ថ្មី ក្នុងចំណោមយុវវ័យ ដោយអង្គការ KHANA។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។






**ប្រធានបទទី១: ឯកឧត្តមវេជ្ជបណ្ឌិត ខា ចៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើសកម្មភាពក្នុងខែសីហា ឆ្នាំ២០១៨ ដូចខាងក្រោម៖

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចុះពិនិត្យវឌ្ឍនភាពក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងខេត្ត សហគមន៍ និងពិនិត្យមើលការបញ្ចូលគ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ នៅខេត្តស្ទឹងត្រែង ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកំពង់ចាម។
- ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីការអង្កេតសន្ទស្សន៍នៃការមាក់ងាយលើអ្នករស់នៅជាមួយមេរោគអេដស៍ ដើម្បីធ្វើបច្ចុប្បន្នភាពស្វែងយល់អំពីការអង្កេត និងការផ្ដល់ជាធាតុចូលព្រមទាំងការណែនាំនានាជួយដល់ការអនុវត្ត និងប្រើប្រាស់លទ្ធផលដែលបានមកពីអង្កេតឈានទៅកាត់បន្ថយការមាក់ងាយចំពោះអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។
- ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមធ្វើបទបង្ហាញពីការប្ដេជ្ញាចិត្តរបស់កម្ពុជាឆ្ពោះទៅសម្រេចបាននូវគោលដៅ៣សូន្យ នៅក្នុងសិក្ខាសាលា "យើងនាំគ្នាចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីបញ្ចប់ជំងឺអេដស៍នៅកម្ពុជានៅឆ្នាំ២០២៥ "ដែលរៀបចំឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយមានអ្នកចូលរួមប្រមាណជា២០០នាក់។
- ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ទីចាត់ការសុខាភិបាលនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការ AHF បានចូលរួមអប់រំផ្សព្វផ្សាយពីស្ថានភាពបច្ចុប្បន្ននៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងការប្រឈមរបស់យុវវ័យនៃកងយោធពលខេមរភូមិន្ទ នៅបញ្ជាការដ្ឋានវេជ្ជកោះ អគ្គបញ្ជាការខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមចំនួន១៥០នាក់។
- អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំពិភាក្សាមួយជាមួយអង្គការដៃគូពាក់ព័ន្ធដោយផ្ដោតទៅលើបញ្ហាជាគន្លឹះមួយចំនួនរួមមាន៖
  - ✓ ការរកឃើញករណីឆ្លងមេរោគអេដស៍ មានការកើនឡើងចំពោះបុរសរួមភេទជាមួយបុរសនិងស្រីស្រស់។

✓ ករណីឆ្លងមេរោគអេដស៍ថ្មីភាគច្រើនជាយុវវ័យក្រោមអាយុចន្លោះពី១៨ឆ្នាំ ទៅ៣០ឆ្នាំ។

✓ ការព្រួយបារម្ភពីបញ្ហាប្រឈមមុខ ពិសេសក្រុមលាក់មុខ និងអ្នករួមភេទសកម្មដែលមិនបានប្រើប្រាស់ស្រោមអនាម័យ។




<u>**ជាលទ្ធផលសម្រេចបាន៖**</u>

✓ ចុះពិនិត្យស្ថានភាពជាក់ស្តែងនៅកន្លែងប្រឈមមុខខ្ពស់ចំពោះក្រុមគោលដៅ នូវករណីរកឃើញឆ្លងមេរោគអេដស៍ថ្មី រួមមានរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ (បានជួបប្រជុំពិភាក្សាការងារជាមួយគណៈកម្មាធិការ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងដៃគូពាក់ព័ន្ធ)។

✓ រៀបចំបង្កើតសារអប់រំផ្សព្វផ្សាយ ទាក់ទងនឹងបញ្ហាមេរោគអេដស៍ ដើម្បីបញ្ចូលក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីកម្រិតបឋមសិក្សា (ថ្នាក់ទី៥ ឡើងទៅ)។

✓ ជំរុញការអប់រំ ផ្សព្វផ្សាយ និងលើកទឹកចិត្តដល់ក្រុមគោលដៅ ដើម្បីផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្ត (ការប្រើប្រាស់ស្រោមអនាម័យ ការធ្វើតេស្តឈាម និងជំងឺកាមរោគផ្សេងៗ)។

➢ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចុះជួបពិភាក្សាជាមួយគណៈកម្មាធិការ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តឧត្តរមានជ័យ ដើម្បីពិនិត្យមើលពីស្ថានភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងបញ្ហាក្រុមប្រឈមនៅក្នុងខេត្ត។

- ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំជាមួយគណៈកម្មាធិការ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តកោះកុង និងមានការចូលរួមពីអង្គការមូលនិធិថែទាំអ្នកជំងឺអេដស៍ (AHF)។ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើ៖
  - ✓ ពិនិត្យមើលស្ថានភាពការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ និងការអនុវត្តគោលនយោបាយ៧ចំណុចរបស់រាជរដ្ឋាភិបាល នៅក្នុងខេត្តកោះកុង។
  - ✓ ពិភាក្សាលើការគាំទ្រក្នុងការជំរុញសេវាឱ្យទៅជិតប្រជាពលរដ្ឋ តាមរយៈការធ្វើតេស្តឈាមរកមេរោគអេដស៍ និងជំងឺអេដស៍ដោយរថយន្តចល័ត។ ជាលទ្ធផល លោកជំទាវអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត បានស្វាគមន៍ និងបង្ហាញពីការគាំទ្រក្នុងការផ្តួចផ្តើមឱ្យមានរថយន្តចល័តធ្វើតេស្តឈាមរកមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងខេត្ត ព្រមទាំងបានប្តេជ្ញាចិត្តរួមគ្នាជាមួយនឹងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឈានឆ្ពោះទៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥ខាងមុខ។

**ផែនការសកម្មភាព និងទិសដៅសម្រាប់អនុវត្តបន្ត**

- រៀបចំធ្វើសិក្ខាសាលាស្តីពីផែនការសកម្មភាព ឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់នៅរាជធានីភ្នំពេញ។
- បន្តចុះអភិបាលកិច្ចលើការងារវិវឌ្ឍរីកចម្រើនក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងខេត្ត សហគមន៍ និងពិនិត្យមើលការបញ្ចូលគ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍នៅខេត្តកែប ខេត្តមណ្ឌលគិរី និងខេត្តបន្ទាយមានជ័យ។
- នឹងរៀបចំកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅផែនការសកម្មភាពឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី១៤និងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។
- រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ២០១៨ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៨។

**ប្រធានបទទី២៖** បទបង្ហាញស្តីពីបញ្ហាប្រឈមរបស់អ្នកជំងឺអេដស៍ ទៅនឹងជំងឺឱកាសនិយមផ្សេងៗ បង្ហាញជូនដោយលោកស្រីវេជ្ជបណ្ឌិត **គី សុខឡុនា** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ៖

អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ភាគច្រើនប្រឈមទៅនឹងជំងឺឱកាសនិយមមួយចំនួន ដូចជាជំងឺរបេង ជំងឺរលាកស្រោមខួរ រលាកថ្លើមប្រភេទបេ និងសេ ជំងឺរលាកថ្លើមពុំរ៉េ ដូចនេះពួកគាត់ត្រូវព្យាបាលនូវជំងឺឱកាសនិយមទាំងនេះជាមុនសិន ទើបឈានទៅដល់ការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

**ប្រធានបទទី៣៖** បទបង្ហាញស្តីពីការឆ្លងមេរោគអេដស៍ថ្មី ក្នុងចំណោមយុវវ័យ បង្ហាញជូនដោយលោក **ជួប សុខចំរើន** តំណាងអង្គការ KHANA៖

ក្នុងការអនុវត្តការឆ្លើយតប៩០ទាំង៣ តាមរបាយការណ៍របស់ UNAIDS បានបញ្ជាក់ថា៩០ ទាំងបីរហូតមកដល់ពេលនេះត្រឹមឆ្នាំ២០១៧ ដែល៩០ទាំង៣ ផ្តោតសំខាន់ទៅលើគោលដៅសម្រាប់ឆ្នាំ២០២០។ ៩០% ទី១ ទើបបាន៧៥% នៃប្រជាជនដែលផ្ទុកមេរោគអេដស៍ ដឹងពីគាត់មានផ្ទុកមេរោគអេដស៍ ៩០% ទី២ បាន៧៩% នៃអ្នកផ្ទុកបានទទួលសេវាព្យាបាល ហើយ៩០ ទី៣ បាន៨១% នៃអ្នកទទួលសេវាមានបន្ទុកមេរោគអេដស៍ថយចុះ នេះជាលក្ខណៈសកល។ របាយការណ៍របស់អង្គការ UNICEF សម្រាប់យុវវ័យ គិតត្រឹមខែកក្កដា ឆ្នាំ២០១៨ គឺមាន ១.៨លាននាក់ ដែលមានអាយុ១០ ទៅ១៩ឆ្នាំ មានផ្ទុកមេរោគអេដស៍សម្រាប់ទូទាំងពិភពលោក។ បើប្រៀបធៀបជាមួយមនុស្សទូទៅដែលផ្ទុកមេរោគអេដស៍ សម្រាប់យុវវ័យមាន៥% នៃចំនួនមនុស្សដែលផ្ទុកមេរោគអេដស៍ និង១៦% បើប្រៀបធៀបជាមួយអ្នកឆ្លងមេរោគអេដស៍ថ្មី។ នៅក្នុងតំបន់ដែលមានផ្ទុកមេរោគអេដស៍ខ្ពស់ ជាយុវវ័យមាននៅក្នុងតំបន់អាហ្វ្រិក និងអាស៊ីខាងត្បូង។ ក្នុងចំណោមយុវវ័យ១.៨លាននាក់ ដែលមានផ្ទុកមេរោគអេដស៍សម្រាប់ទូទាំងពិភពលោក មាន១.៥លាននាក់ នៅតំបន់អាហ្វ្រិក។ សម្រាប់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៧ អត្រាប្រេវ៉ាឡង់ក្នុងចំណោមប្រជាជនអាយុ១៥-៤៩ឆ្នាំមាន: 0.6% (NCHADS HIV Prevalence projection 2017) ស្ត្រីមានផ្ទៃពោះ 0.28% (National HSS among ANC 2014) ស្ត្រីបំរើសេវាកំសាន្តសប្បាយ 3.2% (EW IBBS 2016) បុរសស្រលាញ់បុរស 2.3% (MSM IBBS 2014) អ្នកបំលែងភេទ 5.9% (TG IBBS 2016) អ្នកចាក់គ្រឿងញៀនមាន 15.2% (PWUD/PWID IBBS 2017) អ្នកប្រើប្រាស់គ្រឿងញៀន 5.7% (PWUD/PWID IBBS 2017)។ សម្រាប់ប្រទេសកម្ពុជាសម្រេចបានល្អ ចំពោះ៩០ទាំងបី ៩០% ទី១ សម្រេចបាន៨៣% នៃប្រជាជនដែលផ្ទុកមេរោគអេដស៍ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ ៩០%ទី២ បាន៩៧% នៃអ្នកផ្ទុកបានទទួលសេវាព្យាបាល ហើយ៩០ ទី៣ បាន៨០%។

សម្រាប់រយៈពេល៩០ថ្ងៃ (15 May-August 17, 2018) ដែលអង្គការ KHANA បានធ្វើការអង្កេតលើ៨ខេត្តប៉ែកខាងត្បូងរាជធានីភ្នំពេញ ក្នុងចំណោមស្ត្រីបំរើសេវាកំសាន្តសប្បាយ បុរសស្រលាញ់បុរស និងអ្នកបំលែងភេទ មាន៩៦នាក់មានផ្ទុកមេរោគអេដស៍ (ស្ត្រីបំរើសេវាកំសាន្តសប្បាយចំនួន១៣នាក់ បុរសស្រលាញ់បុរសចំនួន៦៩នាក់ អ្នកបំលែងភេទមាន១៤នាក់) អ្វីដែលបារម្ភគឺអ្នក

ដែលមានអាយុ១៨-៣០ឆ្នាំ មានចំនួនរហូតដល់៧៩នាក់ ហើយអ្នកដែលមានអាយុលើសពី៤១ឆ្នាំ មានតែ៣នាក់ប៉ុណ្ណោះ។

**ប្រធានបទទី៤៖** ការបង្ហាញពីទម្រង់របាយការណ៍សម្រាប់ក្រសួង ស្ថាប័ន រៀបចំធ្វើមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្ហាញជូនដោយ **លោកវេជ្ជ. ទេព ណាវុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ ដើម្បីចងក្រងជារបាយការណ៍រួមរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនដល់សមាជិក សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៨ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨** ។

កិច្ចប្រជុំបានបញ្ចប់ទៅក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨

**បានឃើញ និងឯកភាព**
**អគ្គលេខាធិការ**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

**វេជ្ជ. ឈា សិទ្ធិ**

**អ្នកធ្វើរបាយការណ៍**

**វេជ្ជ. ហេង ហៃ**

20-9-18